# គោលនយោបាយគាំទ្រ អំពើហិង្សា ក្នុងគ្រួសារ។

## យើងនៅទីនេះដើម្បីជួយ។

Momentum ប្តេជ្ញាគាំទ្រអតិថិជនដែលកំពុងជួបប្រទះអំពើហិង្សាក្នុងគ្រួសារ ឬអ្នកដែលប្រឈមនឹងហានិភ័យនៃការជួបប្រទះអំពើហិង្សាក្នុងគ្រួសារ (*អតិថិជនដែលរងប៉ះពាល់*). គោលនយោបាយនេះកំណត់នូវវិធីសាស្ត្ររួមរបស់យើង ដើម្បីផ្តល់ការគាំទ្រដល់អតិថិជនដែលរងប៉ះពាល់ដោយការគោរព ការឆាប់យល់ដឹង និងការយល់ចិត្ត រួមទាំង៖

- ការទទួលស្គាល់កាលៈទេសៈរបស់ពួកគេគឺជារឿងផ្ទាល់ខ្លួនសម្រាប់ពួកគេ ហើយអំពើហិង្សាក្នុងគ្រួសារអាចរួមបញ្ចូលអាកប្បកិរិយាដ៏ធំទូលំទូលាយ
- ការចូលរួម និងការប្រឹក្សាជាមួយអតិថិជនដែលរងប៉ះពាល់ ដើម្បីផ្តល់លទ្ធផលដែលមានគុណប្រយោជន៍
- ផ្តល់សិទ្ធិអំណាចដល់ពួកគេជាមួយនឹងការគាំទ្រ ដើម្បីគ្រប់គ្រងផលប៉ះពាល់ផ្នែកហិរញ្ញវត្ថុ និងជានាព័ត៌មានផ្ទាល់ខ្លួនរបស់ពួកគេ ហើយ
- ប្រាប់ពួកគេអំពីឱ្យបានដឹងអំពីការគាំទ្រផ្នែកហិរញ្ញវត្ថុដែលមានសម្រាប់ពួកគេ។

យើងប្រឆាំងជំទាស់គ្រប់ទម្រង់នៃអំពើហិង្សាក្នុងគ្រួសារ។ ប្រសិនបើទំនាក់ទំនងផ្ទាល់ខ្លួនធ្វើឱ្យអ្នកមានអារម្មណ៍ថា មិនមានសុវត្ថិភាព ឬគ្មានថាមពល អ្នកប្រហែលជាកំពុងជួបប្រទះនឹងអំពើហិង្សាក្នុងគ្រួសារហើយ វា អាចមានក្នុងទម្រង់ជាច្រើន - ចាប់ពីការរំលោភបំពានផ្លូវកាយ និងផ្លូវចិត្ត ការគ្រប់គ្រងហិរញ្ញវត្ថុ ឬការគ្រប់គ្រងខាងចិត្តសាស្ត្រ - ហើយវាអាចកើតឡើងចំពោះអ្នកណាម្នាក់ ដែលមកពីប្រវត្តិណាមួយ។ ប្រសិនបើអ្នកស្ថិតក្នុងស្ថានភាពនេះ ត្រូវចងចាំថាវាមិនមែនជាកំហុសរបស់អ្នកទេ ហើយត្រូវដឹងថាយើងនៅទីនេះដើម្បីគាំទ្រអ្នក។

ប្រសិនបើអ្នកកំពុងជួបប្រទះអំពើហិង្សាក្នុងគ្រួសារ សូមចូលទៅកាន់ 1800respect.org.au ឬទូរសព្ទទៅពួកគេតាមលេខ 1800 737 732។

ប្រសិនបើអ្នកស្ថិតក្នុងសភាពគ្រោះថ្នាក់ភ្លាមៗ សូមទូរសព្ទទៅលេខ 000

## វិធីសាស្ត្ររបស់យើង

ជំហានដំបូង

- ប្រសិនបើអ្នកបង្ហាញថាអ្នកជាអតិថិជនដែលរងប៉ះពាល់ អ្នកនឹងចូលរួមក្នុងកម្មវិធី Keeping Momentum ដែលបានចាត់ទុកដោយឡែកពិសេសរបស់យើង។
- យើងនឹងមិនស្នើសុំឱ្យអ្នកផ្តល់ភស្តុតាងឯកសារនៃអំពើហិង្សាក្នុងគ្រួសារឡើយ។
- ដើម្បីកាត់បន្ថយការពន្យល់ប្រាប់យើងម្តងហើយម្តងទៀតអំពីស្ថានភាពរបស់អ្នក នៅពេលដែលអ្នកស្ថិតនៅក្នុងកម្មវិធី Keeping Momentum ហើយនោះ អ្នកនឹងពាក់ព័ន្ធតែជាមួយក្រុមការងារ Keeping Momentum ប៉ុណ្ណោះ ដែលមានប្រវត្តិ និងបទពិសោធន៍ក្នុងការជួយ។
- អ្នកអាចទាក់ទងមកក្រុមការងារ Keeping Momentum ដោយផ្ទាល់តាមទូរសព្ទលេខ **1300 415 375** ពីថ្ងៃចន្ទ ដល់ថ្ងៃសុក្រ ម៉ោង8ព្រឹក - ម៉ោង6ល្ងាច។

ឯកជនភាព និងសុវត្ថិភាព

- ជាមួយ Momentum ព័ត៌មានរបស់អតិថិជនដែលរងប៉ះពាល់អាចត្រូវបានចូលប្រើប្រាស់ដ៏មានកម្រិតដោយបុគ្គលិកដែលមានការអនុញ្ញាតដោយផ្អែកលើតម្រូវការដើម្បីដឹង។
- ដោយមានការយល់ព្រមពីអ្នក យើងផ្តល់ព័ត៌មានដែលមានកម្រិតអំពីអ្នក (ហើយសូមកុំភ័យព្រួយឱ្យសោះ យើងដឹងថាអ្នកជាអតិថិជនដែលរងប៉ះពាល់) ដល់ភាគីទីបីដែលមានសារៈសំខាន់ចំពោះយើងក្នុងការលក់ថាមពលជូនអ្នក - រួមទាំងអ្នកចែកចាយថាមពល និងអ្នកចែកសំបុត្រតាមផ្ទះ។
- យើងនឹងទាក់ទងអ្នកតាមរយៈវិធីសាស្ត្រទំនាក់ទំនងដែលអ្នកពេញចិត្ត ក្នុងពេលវេលាដែលសាកសមនឹងអ្នក។
- អ្នកអាចដាក់បន្ថែមតម្រូវការពាក្យសម្ងាត់ដាច់ដោយឡែកមួយ បន្ថែមពីលើការគ្រប់គ្រងការចូលប្រើគណនីស្តង់ដាររបស់យើង។

ការបណ្តុះបណ្តាល និងការយល់ដឹងរបស់បុគ្គលិក

- បុគ្គលិក Momentum ទាំងអស់ទទួលការបណ្តុះបណ្តាលការយល់ដឹងអំពីអំពើហិង្សាក្នុងគ្រួសារ។
- បុគ្គលិកដែលនិយាយទល់មុខនឹងអតិថិជនរបស់យើងត្រូវបានផ្តល់ការបណ្តុះបណ្តាលបន្ថែម ដើម្បីធ្វើឱ្យប្រាកដថាការសន្ទនារបស់យើងជាមួយអតិថិជនដែលរងប៉ះពាល់ ត្រូវបានដោះស្រាយដោយការគោរព និងការយល់ចិត្ត ហើយដំណើរការ និងគោលនយោបាយរបស់យើងអាចត្រូវបានប្រើប្រាស់យ៉ាងឆាប់រហ័ស និងមានប្រសិទ្ធភាពដើម្បីគាំទ្រពួកគេ។
- ក្រុមការងារ Keeping Momentum របស់យើងទទួលបានការបណ្តុះបណ្តាលផ្នែកឯកទេសពិសេសបន្ថែម ដើម្បីជួយដោះស្រាយស្ថានភាពអំពើហិង្សាក្នុងគ្រួសារជាក់លាក់បន្ថែមទៀត និងគាំទ្រអតិថិជនដែលរងប៉ះពាល់របស់យើង។

ជំនួយហិរញ្ញវត្ថុ

អតិថិជនដែលរងប៉ះពាល់ទាំងអស់ អាចចូលប្រើប្រាស់ ជម្រើសជំនួយក្នុងបង់ប្រាក់របស់យើង ដែលរួមមាន៖

- ការរៀបចំហិរញ្ញវត្ថុផ្ទាល់ខ្លួនជាលក្ខណៈបុគ្គល
- ព័ត៌មានអំពីជំនួយរដ្ឋាភិបាលដែលអាចរកបាន
- ការគាំទ្របំណុល (រួមទាំងការផ្អាកសកម្មភាពប្រមូលប្រាក់បំណុល)
- ការបញ្ជូនបន្តទៅកាន់ទីប្រឹក្សាហិរញ្ញវត្ថុ និង
- ការពិនិត្យឡើងវិញនៃផែនការ និងពន្ធ ដោយគិតគូរពីការផ្លាស់ប្តូរណាមួយចំពោះលំនាំការប្រើប្រាស់ថាមពលរបស់អតិថិជន។

បណ្តាញគាំទ្រ
យើងក៏អាចបញ្ជូនបន្តអ្នកទៅកាន់សេវាគាំទ្រសមរម្យ បណ្តាញជំនួយខាងក្រៅ
និងធនធានផ្សេងទៀតផងដែរតាមតម្រូវការ រួមទាំងសេវាកម្មនានាដូចខាងក្រោម។

| **ប្រភេទជំនួយ** | **ទីភ្នាក់ងារ** | **ម៉ោង** | **ទំនាក់ទំនង** |
|---|---|---|---|
| គ្រោះថ្នាក់ភ្លាមៗ | ប៉ូលិស<br>ឡានពន្លត់អគ្គិភ័យ<br>ឬឡានសង្គ្រោះបន្ទាន់ | 24 ម៉ោង | 000 |
| ថ្លង់ ឬពិការភាពលើការស្តាប់/ការនិយាយ | សេវាកម្មជាតិផ្នែកប្រាស្រ័យទាក់ទងជាមួយជនពិការ | 24 ម៉ោង | សេវាកម្មជាតិផ្នែកប្រាស្រ័យទាក់ទងជាមួយជនពិការ<br>(ការហៅទូរសព្ទត្រូវបានធ្វើចេញពីគេហទំព័រ) |
| សេវាកម្ម បកប្រែភាសាសរសេរ និងបកប្រែផ្ទាល់មាត់ | សេវាកម្មបកប្រែផ្ទាល់មាត់ | ម៉ោង8ព្រឹក-ម៉ោង7យប់ (ថ្ងៃក្នុងសប្តាហ៍ប៉ុណ្ណោះ) | 1800 497 170 |
| ការប្រឹក្សា និងការគាំទ្រអំពើហិង្សាក្នុងគ្រួសារ | 1800RESPECT | 24 ម៉ោង | 1800 737 732<br>1800respect.org.au |
| ការប្រឹក្សា និងការគាំទ្រអំពើហិង្សាក្នុងគ្រួសារ | Full Stop Australia | 24 ម៉ោង | fullstop.org.au<br>(សូមមើលគេហទំព័រសម្រាប់ព័ត៌មានទំនាក់ទំនង) |
| ការគាំទ្រពីអំពើហិង្សាក្នុងគ្រួសារ | ជំហានសុវត្ថិភាព<br>(Safe Steps ) | 24 ម៉ោង | 1800 015 188<br>safesteps.org.au |
| បញ្ហាហិរញ្ញវត្ថុ និងបំណុល | បណ្តាញទូរសព្ទបំណុលជាតិ | ម៉ោង9:30ព្រឹក-ម៉ោង4:30រសៀល | 1800 007 007<br>ndh.org.au |
| បញ្ហាហិរញ្ញវត្ថុ និងបំណុល | Moneysmart | គេហទំព័រតែប៉ុណ្ណោះ | moneysmart.gov.au |
| ដំបូន្មានផ្នែកច្បាប់ | ជំនួយផ្នែកច្បាប់រដ្ឋវិចថូរៀ | ម៉ោង8ព្រឹក – ម៉ោង6ល្ងាច (សម្រាប់ថ្ងៃក្នុងសប្តាហ៍ប៉ុណ្ណោះ) | 1300 792 387<br>legalaid.vic.gov.au |
| អ្នកផ្តល់សេវាកម្មសុខភាពផ្លូវចិត្ត | Mind Australia | | 1300 286 463<br>1300 554 660 (បណ្តាញទូរសព្ទជំនួយអ្នកថែទាំ)<br>mindaustralia.org.au/about-mind |
| បញ្ជីសេវាកម្មគាំទ្រ (ការគាំទ្រអំពើហិង្សាក្នុងគ្រួសារ ការគាំទ្រផ្នែកច្បាប់ សេវាគាំទ្រការញៀនសុរា និងគ្រឿងញៀន និងទីស្នាក់អាស្រ័យនៅពេលមានវិបត្តិ) | Ask Izzy | គេហទំព័រតែប៉ុណ្ណោះ | askizzy.org.au |

## ឯកសារយោង

វាក៏អាចមានប្រយោជន៍ផងដែរ ក្នុងការអានពីគោលនយោបាយជំនួយការបង់ប្រាក់ របស់យើង និងបណ្តឹងតវ៉ា ហើយនិងគោលនយោបាយដំណោះស្រាយជម្លោះរបស់យើង។

គោលនយោបាយអំពើហិង្សាក្នុងគ្រួសាររបស់យើង ត្រូវបានពិនិត្យចុងក្រោយកាលពីខែមេសា ឆ្នាំ2023 និងបានធ្វើបច្ចុប្បន្នភាពចុងក្រោយនៅថ្ងៃទី 17 ខែឧសភា ឆ្នាំ 2023។